**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
លេខាធិការដ្ឋាន
លេខ ២៣៣ ឧក្រច/០៤

# <u>សូមជម្រាប</u>

## លោកប្រធានរដ្ឋបាលអង្គការស្តារកម្ពុជា

**<u>សូមជ្រាប ។</u>**

**<u>កម្មវត្ថុ:</u>** អំពីការស្នើសុំធ្វើការសម្ភាសជាមួយ ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជីនតុលាការគ្រប់ថ្នាក់ ។
**<u>យោង:</u>** លិខិតលេខ ១៦-២០០៤ តស.រប ស្តារកម្ពុជា ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ២០០៤ របស់អង្គការស្តារកម្ពុជា ។

ខ្ញុំសូមជម្រាបលោកថា លេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពុំមានសមត្ថកិច្ចសម្រេចដោយឯកឯង អនុញ្ញាត ឬ មិនអនុញ្ញាត អោយចៅក្រម ឬព្រះរាជអាជ្ញា ធ្វើបទសម្ភាណាមួយឡើយ ។ សិទ្ធិសម្រេចនេះជាសិទ្ធិ នៃសម័យប្រជុំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។ អ្វីដែលគួរអោយសោកស្តាយ ឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម ពុំអាចដំណើរការប្រជុំបានទេ បើពុំមានព្រះរាជបញ្ជាពីព្រះមហាក្សត្រ ។ក្រឡាបញ្ជី នៃសាលាជម្រះក្តីពុំស្ថិតនៅក្រោមសមត្ថកិច្ច នៃឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រមទេ ។

តាមគោលការណ៍ នៃក្រមសីលធម៌វិជ្ជាជីវៈចៅក្រមតុលាកា និងចៅក្រមអយ្យការ ក្នុងមុខដំណែងមិនត្រូវធ្វើបទសម្ភាបកស្រាយច្បាប់ ឃោសនា និងផ្សព្វផ្សាយអំពីទស្សនៈរបស់ខ្លួនទេ ។

លេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានការសោកស្តាយយ៉ាងខ្លាំងដោយពុំមានលទ្ធភាពបំពេញតាមសំណូមពររបស់លោក ដូចមានក្នុងលិខិតដូចយោងខាងលើ ។

សូម លោកប្រធាន ទទួលនូវសេចក្តីរាប់អាន ដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

ភ្នំពេញថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០៤
**ត.ប លេខាធិការ**
**ប្រធាននាយកដ្ឋានជំនួយការកិច្ចការតុលាការ**

**អ៊ិច គីមស្រ៊ី**

<u>ចម្លងជូន</u>
-គ្រប់តុលាការ និង អយ្យការ